**ទស្សនៈអ្នកនិពន្ធ**

វ៉ុលេ៣, លេខ៨, ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១

# ភាពគ្រោះថ្នាក់នៃការរារាំងចំពោះការបិទខ្ទប់ប្រឆាំងជំងឺកូវីដ១៩

អ៊ុន ឃាង *

រលកនៃការឆ្លងរីករាលដាលក្នុងសហគមន៍នៃជំងឺកូវីដ១៩ នាពេលបច្ចុប្បន្ន និងគោលនយោបាយបិទខ្ទប់របស់រាជរដ្ឋាភិបាលជាអកុសលបានកើតឡើងចំពេលថ្ងៃខួបនៃយុគសម័យខ្មៅដ៏ងងឹតនៃការដណ្ដើមយករាជធានីភ្នំពេញរបស់ខ្មែរក្រហម។ ភ្លាមៗនោះ មនុស្សមួយចំនួនតូច បានធ្វើការប្រៀបធៀបរវាងការបិទខ្ទប់ និងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដោយបានបង្ហោះរូបភាពដងវិថីដ៏ទទេរស្អាត និងស្ងប់ស្ងាត់នៅក្នុងទីក្រុង អមជាមួយនឹងរូបភាពដែលផ្ដិតយកទិដ្ឋភាពទីក្រុងនាថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ តាមរយៈបណ្ដាញផ្សព្វផ្សាយសង្គម។ ដោយសារតែការព្រួយបារម្ភ និងភាពមិនចេះអត់ធ្មត់របស់ពួកគេពាក់ព័ន្ធនឹងការបិទខ្ទប់ វាជារឿងដែលគេអាចស្រមៃបាន ថាមនុស្សធម្មតាអាចនឹងធ្វើការប្រៀបធៀបបែបនេះ។ ប៉ុន្តែ អ្វីដែលគេមិនអាចស្រមៃបាននោះ គឺការឮចេញពីមាត់របស់មេដឹកនាំអតីតគណបក្សប្រឆាំង ដែលបានប្រៀបធៀបយន្តការបិទខ្ទប់របស់រដ្ឋាភិបាលក្នុងការដោះស្រាយវិបត្តិជំងឺកូវីដ១៩ ទៅនឹងការជម្លៀសប្រជាជនរបស់ពួកខ្មែរក្រហម។ គោលនយោបាយបិទខ្ទប់ មិនមែនជាមនោគមវិជ្ជាអចិន្ត្រៃយ៍ភាព ដែលអាចយកមកប្រៀបធៀបជាមួយមនោគមវិជ្ជាអចិន្ត្រៃយ៍ភាពជ្រុលនិយម របស់ខ្មែរក្រហមដែលបានរុញច្រានកម្ពុជាឱ្យធ្លាក់ក្នុងនរកលើផែនដី និងសម្លាប់ប្រជារាស្ត្រខ្មែរជាង ១ ភាគ៤ ដោយការសម្លាប់ ការអត់ឃ្លាន ជំងឺ និងភាពនឿយហត់នោះឡើយ។ ផ្ទុយទៅវិញ ការបិទខ្ទប់ គឺជាគោលនយោបាយបែបវិទ្យាសាស្ត្រ សំដៅជួយសង្គ្រោះប្រជាជនកម្ពុជា មិនមែនជាការធ្វើទុក្ខបុកម្នេញទៅដល់ពួកគេឡើយ។ ការអំពាវនាវមិនឱ្យប្រជាជនគោរពតាមគោលនយោបាយបិទខ្ទប់ គឺជាអំពើឆ្លៀតឱកាសដើម្បីកេងចំណេញផ្នែកនយោបាយជាមួយនឹងគោលបំណងបង្កឱ្យមានភាពចលាចលសង្គម ដែលប្រាសចាកពីអំពើល្អទាំងឡាយ។ ភស្តុតាងពីប្រទេសមួយចំនួនដូចជា ណូវែលសេឡង់ និងអូស្ត្រាលី បង្ហាញថាការបិទខ្ទប់បានទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ យ៉ាងជោគជ័យ។ ផ្ទុយស្រឡះ ការបដិសេធរបស់រដ្ឋាភិបាល ក្នុងការបិទខ្ទប់ បាននាំឱ្យការឆ្លងរាលដាលនៃវីរុស ភ្ជាប់ជាមួយនឹងផលប៉ះពាល់សង្គម និងសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ ដូចបានឃើញនៅប្រេស៊ីល និងសហរដ្ឋអាមេរិកក្រោមរដ្ឋការប្រធានាធិបតី ត្រាំ។

ប្រាកដណាស់ ភាពលំបាក ពិតជាកើតឡើងពីការអនុវត្តគោលនយោបាយបិទខ្ទប់។ ទីមួយ ការបិទខ្ទប់ប៉ះពាល់ដល់ការរស់នៅ និងជីវភាពប្រចាំថ្ងៃរបស់ប្រជាជន ដោយសារការរាំងស្ទះលើការធ្វើដំណើរ ធ្វើឱ្យប្រជាជនមិនអាចទទួលបានទំនិញ ឬសម្ភារ បំពេញការងារ និងធ្វើអាជីវកម្ម ឬជួញដូរបាន។ ក្នុងគោលបំណងសម្រាប់ប្រើប្រាស់ជាផលចំណេញផ្នែកនយោបាយ មេដឹកនាំអតីតគណបក្សប្រឆាំង បានបំប៉ោងរឿងនេះឱ្យកាន់តែធំជាងភាពជាក់ស្ដែង ដោយអះអាងថាប្រជាជនកំពុងមានការអត់ឃ្លាន។ តាមការពិតទៅ មិនមានរបាយការណ៍ណាមួយ ស្ដីពី ការអត់ឃ្លានរបស់ប្រជាជនក្នុង

*លោកបណ្ឌិត អ៊ុន ឃាង គឺជាសាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រនយោបាយ នៅសាកលវិទ្យាល័យ Northern Illinois សហរដ្ឋអាមេរិក និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

© *រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។*

អំឡុងពេលបិទខ្ទប់នេះឡើយ។ រដ្ឋាភិបាល បានដាក់ចេញយុទ្ធសាស្ត្រមួយចំនួន ដើម្បីដោះស្រាយកង្វះស្បៀងអាហារ និងទប់ស្កាត់ការឡើងថ្លៃទំនិញហួសហេតុ ដោយបញ្ជាឱ្យក្រសួងពាណិជ្ជកម្ម ដាក់លក់ម្ហូបអាហារ និងសម្ភារចាំបាច់ជូនដល់ប្រជាជន។ ខ្ញុំយល់ស្របថា រដ្ឋាភិបាលគួរតែផ្តល់របស់ចាំបាច់ទាំងនេះដោយឥតគិតថ្លៃ។ យ៉ាងណាក្តី រដ្ឋាភិបាលណាក៏ដោយ ដូចគ្នាទៅនឹងប្រជាជនទូទៅដែរ គឺតែងមានកម្រិតហិរញ្ញវត្ថុ។ គេគួរសម្គាល់ថា រដ្ឋាភិបាល ធ្លាប់បានផ្តល់អាហារដល់ប្រជាជនក្រីក្រ។ សកម្មភាពនេះ គួរតែត្រូវបានកោតសរសើរ មិនមែនមើលរំលងនោះឡើយ។

ការបិទខ្ទប់ មិនមានន័យថា ជាការផ្អាករាល់គ្រប់សកម្មភាពទាំងស្រុងឡើយ។ សេវាកម្មចាំបាច់មួយចំនួនដូចជា មន្ទីរពេទ្យ ធនាគារ និងផ្សារ (ទោះបីជាមានការរៀបចំសាជាថ្មីដើម្បីអនុលោមតាមគោលការណ៍ការពារជំងឺកូវីដ១៩ បានត្រឹមត្រូវ) នៅតែបន្តដំណើរការ។ បើតាមអ្វីដែលមេដឹកនាំរូបនេះបានចោទប្រកាន់ថែមទៀតនោះ ការបន្តអនុញ្ញាតឱ្យធនាគារបើកទ្វារអំឡុងពេលនៃជំងឺរាតត្បាតសកលនេះ គឺជាការឃុបឃិតរវាងរដ្ឋាភិបាល និងម្ចាស់ធនាគារ។ ការអះអាងបែបនេះ គឺមិនសមហេតុផលទាល់តែសោះ ហើយថែមទាំងខុសពីការពិតទាំងស្រុង។ ផ្អែកលើទ្រឹស្តីសេដ្ឋកិច្ច និងស្មារតីនៃការជួយប្រទេសជាតិ និងផ្ទុយពីការលើកឡើងរបស់មេដឹកនាំអតីតគណបក្សប្រឆាំង ធនាគារគួរតែបន្តប្រតិបត្តិការរបស់ខ្លួន។ ស្ថាប័នធនាគារ គឺជាផ្នែកមួយដ៏សំខាន់នៃសេដ្ឋកិច្ចកម្ពុជាក្នុងយុគសម័យនៃសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងសាកល។ ដូចនេះ ការបិទធនាគារទាំងស្រុង នឹងបង្កការរំខានដល់សេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ និងអាចរុញច្រានសេដ្ឋកិច្ចកម្ពុជាឱ្យធ្លាក់ចូលក្នុងវិបត្តិសេដ្ឋកិច្ចទៀតផង។ ស្ថានភាពនេះ នឹងបន្ថែមទម្ងន់ទុក្ខដល់ប្រជាជនកម្ពុជាកាន់តែខ្លាំងឡើង ហើយជាពិសេសនោះ អ្នកដែលមានបន្ទុកក្នុងការដោះបំណុល នឹងជួបការលំបាកច្រើនជាងគេ។ ការជជែកវែកញែកអំពីវិធីដែលម្ចាស់បំណុល និងរដ្ឋាភិបាលគួរជួយកូនបំណុលរបៀបណាដើម្បីឱ្យពួកគេ បំពេញកាតព្វកិច្ចក្នុងការសងបំណុល ដោយមិននាំឱ្យមានវិបត្តិហិរញ្ញវត្ថុ គួរជាអ្វីដែលមេដឹកនាំ និងប្រជាជនប្រកបដោយទំនួលខុសត្រូវ គួរតែមាន និងត្រូវតែមាន។

ជំងឺរាតត្បាតកូវីដ១៩ បានបង្កឱ្យមានការបំផ្លិចបំផ្លាញផ្នែកសង្គម និងសេដ្ឋកិច្ចនៅទូទាំងសាកលលោក។ គោលនយោបាយ និងយុទ្ធសាស្ត្រ ដើម្បីបញ្ឈប់ការរីករាលដាលនៃវីរុសបានធ្វើឱ្យរដ្ឋាភិបាលមួយចំនួនស្ថិតក្នុងស្ថានភាពដ៏លំបាក។ ការដោះដូររវាងការលះបង់រយៈពេលខ្លី និងផលចំណេញរយៈពេលវែង គឺចាំបាច់បំផុតនៅក្នុងកាលៈទេសៈដ៏លំបាកមួយនេះ។ ការអនុវត្តការបិទខ្ទប់ គឺជាការលះបង់ដ៏ចាំបាច់ ដែលសង្គមត្រូវតែស៊ូទ្រាំ ដើម្បីបញ្ចៀសមហន្តរាយផ្នែកសុខភាពក្នុងរយៈពេលវែង សម្រាប់ប្រទេសជាតិ។ ដើម្បីសម្រេចបាននូវគោលបំណងទាំងឡាយ គុណវិបត្តិ នៅក្នុងអំឡុងពេលអនុវត្ត គឺចៀសមិនផុតឡើយ។ ហេតុដូចនេះ ការរិះគន់ដើម្បីស្ថាបនា ជាការចាំបាច់។ យ៉ាងណាក៏ដោយ ការចោទប្រកាន់ថា ថ្នាក់ដឹកនាំរដ្ឋាភិបាល បានអនុវត្តគោលនយោបាយក្នុងគោលបំណង ដើម្បីធ្វើបាបប្រជាជនខ្លួនឯង និងដើម្បីពង្រឹងគ្រួសារខ្លួន គឺជាការចោទប្រកាន់ដែលគ្មានទំនាក់ទំនងនឹងគ្នាសោះ និងពោរពេញទៅដោយភាពគ្រោះថ្នាក់ទៅវិញ។

Cambodia Development Center
Cambodia Development Center (@cd.centerkh)
Cambodia Development Center
Cambodia Development Center (t.me/cdcenterkh)
Building E, University of Puthisastra, #55, Street 180-184, Sangkat Boeung Raing, Khan Daun Penh
info@cd-center.org | (+855) 10 950 456 www.cd-center.org

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center